RAC Ratings

របាយការណ៍វាយតម្លៃលទ្ធភាពសង
លេខៈ ០០២/២៥
ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥

# ស៊ីអាយអេ ហ្វឹស អ៊ិនធើណេសិនណល ស្គូល

| ចំណាត់ថ្នាក់ឥណទាន | | ព័ត៌មានសញ្ញាបណ្ណ | |
|---|---|---|---|
| ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន | khBB | ទំហំ | ១០ លានដុល្លាអាមេរិក |
| ទស្សនវិស័យ | **អវិជ្ជមាន** | ចំនួននៃការទូទាត់ | ប្រចាំឆមាសសម្រាប់ការទូទាត់ការប្រាក់ និងប្រចាំឆ្នាំសម្រាប់ការទូទាត់ប្រាក់ដើម |
| ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | khAAA | រយៈពេលឥណប្រតិទាន | ៥ឆ្នាំ(មិនមានការទូទាត់ប្រាក់ដើមរយៈពេល១ឆ្នាំ) |
| | | ប្រភេទ | មិនមានទ្រព្យតម្កល់ មិនបន្ទាប់បន្សំ ប៉ុន្តែមានបុគ្គលធានា |
| | | អត្រាគូប៉ុង | ៥,៦% ក្នុងមួយឆ្នាំ |
| | | បុគ្គលធានា | Credit Guarantee & Investment Facility (CGIF) |

## អ្នកវាយតម្លៃ៖


លោក ស៊ីសុវត្ថិ ចក្រការា CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

កញ្ញា សៀង ដារីយ៉ា
s.darya@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៨៦ ៧៧៧

កញ្ញា ពៅ ស៊ុនវណ្ណដែត
p.sunvandeth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣១៨ ៧៧៧

កញ្ញា លឹម អច្ឆរាទេពី
l.achhakratepy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៩៩៣ ៣៣៧


## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

ឯកសារមួយចំនួន ដែលបានប្រើប្រាស់ក្នុងការវាយតម្លៃបច្ចុប្បន្ន គឺនៅក្នុងទម្រង់ជាសេចក្តីព្រាង ។ ដូច្នេះ ការវាយតម្លៃបច្ចុប្បន្ន គឺជាការវាយតម្លៃបណ្តោះអាសន្ន ដែលផ្អែកលើឯកសារចុងក្រោយ ដែលមិនមានភាពខុសគ្នាពីព័ត៌មានដែលប្រើជាឯកសារយោងក្នុងរបាយការណ៍វាយតម្លៃនេះ។

យើងផ្តើមការវាយតម្លៃលទ្ធភាពសងរបស់ ស៊ីអាយអេ ហ្វឹស អ៊ិនធើណេសិនណល ស្គូល ("សញ្ញាបណ្ណ") ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ (BCR) **"khAAA"** (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ «*សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ*»។

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរ៖ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ SACP វិភាគទម្រង់ឥណទានតាមរយៈហានិភ័យអាជីវកម្ម និងហានិភ័យហិរញ្ញវត្ថុរបស់ CIA។ ក្នុងករណីនេះ ការវាយតម្លៃ SACP របស់ CIA ចំណាត់ថ្នាក់ **"khBB"** បង្ហាញពីទម្រង់ «ហានិភ័យ-មធ្យម» ។

កត្តាគាំទ្រខាងក្រៅអាចបង្កើតបានដោយភាគីពាក់ព័ន្ធដូចជា ក្រុមហ៊ុនមេ ឬ ក្រុមហ៊ុនហូលឌីង (Group Support) ឬដោយអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល (Country Support)។ ក្នុងករណី CIA ទាំងកត្តាគាំទ្រខាងក្រៅ របស់ Group និង Country Support មិនមានភាពរឹងមាំគ្រប់គ្រាន់ ដើម្បីជានាតម្លើងចំណាត់ថ្នាក់ឡើយ។ ដូច្នេះ ICR នៅរក្សាចំណាត់ថ្នាក់ **"khBB"** ។

សញ្ញាបណ្ណនេះទទួលបានការធានាពី CGIF ជាស្ថាប័នពាក់ព័ន្ធរបស់ ADB ដែលទទួលបាន ចំណាត់ថ្នាក់ឥណ-ទានក្រុមហ៊ុន "AA" ដោយ S&P Global Ratings។ តាមទស្សនៈរបស់យើង សេចក្តីព្រាងរបស់កិច្ចព្រមព្រៀងធានាបង្ហាញអំពីភាពត្រឹមត្រូវនៃការជំនួសឥណទានពី ICR នៃ ស៊ីអាយអេ ហ្វឹស អ៊ិនធើណេសិនណល ស្គូល ដោយ ICR នៃ CGIF។ ក្នុងករណីមានការខកខានសងបំណុល ម្ចាស់បំណុលត្រូវបានការពារដោយការធានាដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌនៃការទូទាត់ឱ្យទាន់ពេលវេលានូវប្រាក់ដើម និងការប្រាក់ដោយ CGIF។


©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៥
©Copyright 2025, RATING AGENCY OF (CAMBODIA) PLC. All rights reserved.


អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ(បន្ត)

នៅក្នុងលក្ខខណ្ឌនេះ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ គឺ **"khAAA"** (ចំណាត់ថ្នាក់ជាតិ) អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានា ដែលនឹងចូលជាធរមាន។

## ទស្សនវិស័យ

ប្រាក់ចំណូល ត្រូវបានរំពឹងថាកើនឡើងយ៉ាងរលូន ជាមួយនិងការបើកដំណើរការ សាលា ស៊ីអាយអេ ហ្វឺស សាខាទីបួន (ដំណាក់កាលទីមួយ) នៅត្រីមាសទីបី ឆ្នាំ២០២៥ បន្ទាប់មកដំណាក់កាលទីពីរ នៅកំឡុងឆ្នាំក្រោយ។ ទោះជាយ៉ាងណា ផលចំណេញនឹងត្រូវបានថយចុះ ដោយសារការរងសម្ពាធ ពីការពង្រីកផែនការ ដូចដែលបានមើលឃើញនៅក្នុងការបើកសាខាមុនៗ ដែលធ្វើឱ្យចំណាយប្រតិបត្តិការកើនឡើង។ ជាមួយនឹងការបោះផ្សាយសញ្ញាបណ្ណទីពីរ និងការបង្កើនប្រាក់កម្ចី ចំនួន ៥លានដុល្លារក្នុងដំណាក់កាលដែលបានគ្រោងទុក ទំហំបំណុល របស់ CIA នឹងកើនឡើងយ៉ាងខ្លាំង។ បន្ថែមលើពីនេះ នៅឆ្នាំ ២០២៥ ក្រុមហ៊ុនមានផែនការបែងចែកភាគលាភដល់ ម្ចាស់ភាគហ៊ុនចំនួន ៦លានដុល្លារ ជាសាច់ប្រាក់ ដែលទទួលបានការអនុម័តពី CGIF និងធនាគារផ្តល់ប្រាក់កម្ចីនៅក្នុងប្រទេស។ ទោះបីជា មានបំណុលទាំងនេះក៏ដោយ CIA រំពឹងថានឹងអាចបំពេញកាតព្វកិច្ចទូទាត់ប្រាក់បំណុលបាន ទោះបីភាពបត់បែនផ្នែកហិរញ្ញវត្ថុនៅមានកម្រិត។

## កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ដើម្បីពិចារណាលើការបង្កើនឡើងនូវចំណាត់ថ្នាក់ ICR របស់ក្រុមហ៊ុនឱ្យប្រសើរឡើង យើងត្រូវការតាមដាននិងពិនិត្យជាក់ស្តែង លើការបង្កើនប្រាក់ចំណេញជាបន្តបន្ទាប់ និងការកាត់បន្ថយនូវទំហំបំណុលរបស់ ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល។ ក្នុងករណីដែល ប្រាក់ចំណេញដែលមានការថយចុះ ការកើនឡើងនៃទំហំបំណុល និងការបែងចែកភាគលាភច្រើន អាចបណ្តាលឱ្យយើងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ ICR។

ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ យោងចំណាត់ថ្នាក់ជាសកលរបស់ CGIF (AA ដោយ S&P Global Ratings) ។ ដូច្នេះ យើងអាចពិចារណាលើការបន្ទាបចំណាត់ថ្នាក់ BCR ប្រសិនបើការវាយតម្លៃជាសកលរបស់ CGIF ត្រូវបានបន្ទាបចំណាត់ថ្នាក់។

## បញ្ហាដែលត្រូវត្រួតពិនិត្យ

ទំហំបំណុលរបស់ CIA ផែនការពង្រីក ចំនួនចុះឈ្មោះចូលរៀន ការប្រើប្រាស់ឱ្យអស់ពីលទ្ធភាព និងផែនការបែងចែកភាគលាភ គឺជាចំណុចដ៏សំខាន់ដែលត្រូវត្រួតពិនិត្យ និងតាមដានផងដែរ។

## សេចក្តីសង្ខេបអំពី ស៊ីអាយអេ ហ្វឺស អ៊ិនធើណាសិនណល ស្គូល

## ទិដ្ឋភាពទូទៅ

ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល (ហៅកាត់ថា "CIA") គឺជាសាលាឯកជនអន្តរជាតិមួយក្នុងប្រទេសកម្ពុជា ដែលផ្តល់កម្មវិធីអប់រំចាប់ពីមុនថ្នាក់មត្តេយ្យដល់វិទ្យាល័យ ។ CIA ត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្នុងឆ្នាំ ២០១៦។ CIA ទទួលបានអាជ្ញាប័ណ្ណពីក្រសួងអប់រំ យុវជន និងកីឡា (MoEYS)។ បន្ថែមពីនេះ សាលាក៏ត្រូវបានទទួលស្គាល់ដោយ The Accrediting Commission for Schools, Western Association of Schools and Colleges (ACS WASC), Quality Matters, និង The Institute for Habits of Mind។ បច្ចុប្បន្ន CIA មានសាខាចំនួនបី៖ CIA FIRST សែនសុខ(Pre-K3-G8) វិទ្យាល័យ CIA FIRST សែនសុខ(G9-G12) និង CIA First ច្បារអំពៅ(Pre-K3-G12)។ CIA គ្រោងនឹងបើកដំណើរការ សាខាទីបួន(ដំណាក់កាលទីមួយ) ដែលទទួលបានអាជ្ញាបណ្ណនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ មានទីតាំងនៅខណ្ឌឫស្សីកែវ ក្នុងត្រីមាសទីបី ឆ្នាំ២០២៥ ។

## ការប្រតិបត្តិ

CIA រក្សាបានប្រាក់ចំណេញសុទ្ធក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ បើទោះបីជាប្រាក់ចំណេញបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ ២០២១ ដោយសារតែការបើកសាខាទីពីរ (CIA FIRST ច្បារអំពៅ) ក្នុងខែកញ្ញា ឆ្នាំ ២០២០ និងសាខាទីបី (វិទ្យាល័យ CIA FIRST សែនសុខ) នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២១។ ការពង្រីកនេះ នាំឱ្យមានការកើនឡើងយ៉ាងខ្លាំង លើការចំណាយរំលស់ និងចំណាយថេរផ្សេងទៀត ដើម្បីដំណើរការសាខាថ្មី។ យ៉ាងណាក៏ដោយ ផលចំណេញមានការស្ទុះឡើងយ៉ាងខ្លាំងក្នុងឆ្នាំ ២០២៣ និង ២០២៤ ទោះបីជាមានការធ្លាក់ចុះតិចតួចនៅឆ្នាំ ២០២៤ ដែលភាគច្រើនកើតចេញពីការកើនឡើងយ៉ាងរហ័សនៃចំណាយបុគ្គលិក។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៥
©Copyright 2025, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

## ការប្រតិបត្តិ (បន្ត)

សម្រាប់ CIA សន្ទនីយភាព វាស់វែងដោយសាច់ប្រាក់ក្នុងដៃគិតជាថ្ងៃប្រចាំខែ មានការប្រែប្រួលខ្លាំងសម្រាប់ CIA ដោយសារតែការឡើងចុះនៃសាច់ប្រាក់ និងការវិនិយោគរយៈពេលខ្លីនៅលើតារាងតុល្យភាព។ អនុបាតធ្លាក់ចុះនៅក្នុង ឆ្នាំ២០២៤ បង្ហាញពីការកាត់បន្ថយសមត្ថភាពក្នុងការទ្រទ្រង់លើចំណាយប្រតិបត្តិការប្រចាំឆ្នាំដែលកំពុងកើនឡើង។ ក្រៅពីនេះ អនុបាតរក្សាបាននៅកម្រិតមធ្យម ។

CIA មិនមានគោលដៅរចនាសម្ព័ន្ធដើមទុន នៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ អនុបាតបំណុល/ដើមទុន របស់ក្រុមហ៊ុន ស្ថិតនៅក្រោម ៥០% ពីឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ លើកលែងតែឆ្នាំ ២០២៤ នៅពេលការបោះផ្សាយសញ្ញាបណ្ណដំបូង នាំឱ្យការកើនឡើងនៃទំហំបំណុលរបស់ CIA ឡើងដល់ ៥០,១%។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៥
©Copyright 2025, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

| | ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២២<br>ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៣<br>ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៤<br>ដុល្លារអាមេរិក |
|---|---|---|---|
| **របាយការណ៍ចំណេញ/ខាត** | | | |
| ចំណូលការប្រាក់ | 17,839,571 | 23,247,453 | 28,284,894 |
| ចំណេញដុល | 7,036,807 | 10,977,903 | 13,122,216 |
| ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ | 2,382,052 | 6,919,794 | 6,550,352 |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | 705,086 | 5,568,844 | 4,925,734 |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | |
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 12,502,896 | 9,273,472 | 7,157,250 |
| ទ្រព្យ និងបរិក្ខារ | 33,930,555 | 32,473,437 | 38,967,465 |
| ទ្រព្យសកម្មដែលមានសិទ្ធប្រើប្រាស់ | 9,405,605 | 11,685,534 | 18,277,740 |
| **ទ្រព្យសកម្មសរុប** | 57,175,069 | 56,691,451 | 72,041,041 |
| **បំណុល** | | | |
| បោះផ្សាយមូលបត្របំណុល | | | |
| បំណុលភតិសន្យា | 10,566,444 | 13,139,708 | 20,573,161 |
| **បំណុលរយៈពេលវែង** | **17,738,838** | **18,005,737** | **33,561,050** |
| ប្រាក់កម្ចី | 1,771,054 | 3,434,889 | 1,540,677 |
| បំណុលក្នុងកិច្ចសន្យា-ថ្លៃសិក្សានិងថ្លៃផ្សេងៗ | 12,302,063 | 5,632,282 | 6,789,604 |
| **បំណុលរយៈពេលខ្លី** | **14,830,833** | **10,511,472** | **10,380,015** |
| **បំណុលសរុប** | **32,569,671** | **28,517,209** | **43,941,065** |
| **មូលធនសរុប** | | | |
| ដើមទុន | | | |
| បុព្វលាភភាគហ៊ុន | 1,280,000 | 1,280,000 | 1,280,000 |
| ប្រាក់ចំណេញរក្សាទុក | 14,720,000 | 14,720,000 | 14,720,000 |
| **មូលធនសរុប** | **24,605,398** | **28,174,242** | **28,099,976** |
| **បំណុលនិងមូលធនសរុប** | **57,175,069** | **56,691,451** | **72,041,041** |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | |
| សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ | 9,912,594 | 2,609,023 | 8,923,473 |
| សាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ | (1,345,594) | (3,041,521) | (12,535,733) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | (1,569,380) | (2,796,926) | 1,496,038 |
| **ការកើនឡើង/ថយចុះ សាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | **6,997,620** | **(3,229,424)** | **(2,116,222)** |

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៥
©Copyright 2025, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

| ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ) | | | |
|---|---|---|---|
| **ចំណាត់ថ្នាក់ជាតិ** | **និយមន័យ** | | |
| khAAA | សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ១ | ហានិភ័យទាបណាស់ |
| khAA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ២ | |
| khA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៣ | ហានិភ័យទាប |
| khBBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៤ | |
| khBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៥ | ហានិភ័យមធ្យម |
| khB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៦ | |
| khCCC | សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល | ៧ | ហានិភ័យខ្ពស់ |
| khCC | សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៨ | |
| khC | ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៩ | ហានិភ័យខ្ពស់ណាស់ |
| khD | មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់ | ១០ | |

**សេចក្ដីថ្លែងមិនទទួលខុសត្រូវ**

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៥
©Copyright 2025, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website